

# ព្រះយេស៊ូវគ្រីស្ទបានទទួលពិធីបុណ្យជ្រមុជទឹក

យ៉ូហាន បាទីស្ទ គឺជាព្យាការីម្នាក់ ។ លោកប្រាប់ប្រជាជនអំពីព្រះយេស៊ូវគ្រីស្ទ ។ ថ្ងៃមួយ យ៉ូហានបានជ្រមុជទឹកឲ្យមនុស្សនៅក្នុងទន្លេយ័រដាន់ ។ បន្ទាប់មកព្រះយេស៊ូវបានយាងមកដល់ ។ ទ្រង់បានបង្គាប់ឲ្យយ៉ូហានជ្រមុជទឹកឲ្យទ្រង់ ។

ព្រះយេស៊ូវ បានមានព្រះបន្ទូលថាព្រះវរបិតាសួគ៌ បានដាក់បទបញ្ញត្តិឲ្យមនុស្សទាំងអស់ទទួលពិធីបុណ្យជ្រមុជទឹក ។ ទ្រង់ចង់គោរពតាមព្រះវរបិតាសួគ៌ ។ ទ្រង់ចង់ធ្វើជាគំរូសម្រាប់យើង ។

យ៉ូហានបានជ្រមុជទឹកឲ្យព្រះយេស៊ូវនៅក្នុងទន្លេយ័រដាន់ ។ នៅពេលព្រះយេស៊ូវយាងចេញពីទឹក ប្រជាជនបានឮសំឡេងរបស់ព្រះវរបិតាសួគ៌ ។ ទ្រង់មានព្រះបន្ទូលថា« នេះជាកូនស្ងួនភ្ងាយើង ជាទីគាប់ចិត្តយើងណាស់ » ។

យើងអាចធ្វើតាមគំរូរបស់ព្រះយេស៊ូវបាន តាមរយៈការទទួលពិធីបុណ្យជ្រមុជទឹក ។ ព្រះវរបិតាសួគ៌សព្វព្រះទ័យនៅពេលយើងធ្វើតាមព្រះរាជបុត្រារបស់ទ្រង់ ។ ●

សូមហែកទំព័រនេះចេញ ហើយបត់វាជាពីរ ។ បន្ទាប់មកសូមលើករូបភាពឡើងនៅពេលប្អូននិទានរឿងនោះ ។




*អ្នកអាចអានដំណើររឿងនេះនៅក្នុង ម៉ាថាយ ៣ ។*



គូររូបដោយ ហ្គ្រេកខេ.អុលសិន

